# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅ
## សកម្មភាពឆ្នាំ២០១៩របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨

- សូមគោរពគណៈអធិបតី
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋានកាកបាទក្រហមកម្ពុជា និងរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រីមកពីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋានកាកបាទក្រហមកម្ពុជា និងរាជធានី ខេត្ត និង
- អស់លោក លោកស្រីជាភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងសន្និបាតនៅពេលនេះ

ថ្ងៃនេះ ជាថ្មីម្តងទៀត ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអតិបរមាដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ “**សន្និបាតបូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅសកម្មភាពឆ្នាំ២០១៩របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**” ដ៏មហោឡារិកនេះ។

ឆ្លៀតក្នុងឱកាសដ៏មានសារៈសំខាន់នេះ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រីជាភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានចូលរួមក្នុង "**សន្និបាតបូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅសកម្មភាពឆ្នាំ២០១៩របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**" របស់យើង។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាអង្គសន្និបាតជ្រាបថា កាលពីម្សិលមិញ យើងទាំងអស់គ្នាបានជួបជុំគ្នានៅក្នុង "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨**" ដោយបានពិភាក្សា និងអនុម័តរួចទៅហើយនូវសេចក្តីសម្រេចចំនួន៨ចំណុច ដែលអាចប្រើប្រាស់ជាទស្សនទានក្នុងការរៀបចំផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងឆ្នាំ២០១៩ខាងមុខ។

ដូច្នេះនៅក្នុងអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅព្រឹកនេះ យើងនឹងមានរបៀបវារៈថ្មីមួយទៀត ដើម្បីធ្វើបទបង្ហាញជូនអង្គសន្និបាតទាំងមូលស្តីពីរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨ និងទិសដៅជាគោលការណ៍ក្នុងការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០១៩-២០២៣) រួមជាមួយនឹងការចូលរួមបង្ហាញនូវមេរៀនជាបទពិសោធន៍ដោយឡែក និងជាក់ស្តែងដែលបានចងក្រងដោយសមាជិកសមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលក្នុងនោះមានបទបង្ហាញពីក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា និងបទបង្ហាញពីខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ រួមជាមួយនឹងបទបង្ហាញពីអង្គការមិនមែនរដ្ឋាភិបាលតំណាងដោយអង្គការ AHF ផងដែរ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តជូនសមាជិកសមាជិកាអង្គសន្និបាតទាំងមូលចូលរួមផ្តល់ជាយោបល់ ជាអនុសាសន៍ ជាមេរៀន ឬជាបទពិសោធន៍នានាបន្ថែមទៀត ដើម្បីជាការចែករំលែកនូវចំណេះដឹង ជំនាញ និងបទពិសោធន៍ពីការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅតាមស្ថាប័នរបស់ខ្លួន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ខ្ញុំមានជំនឿថា រយៈពេលមួយព្រឹកនេះ អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗ ដែលបានមកពីការអនុវត្តជាក់ស្តែង របស់សមាជិកសមាជិកានៃអង្គសន្និបាតទាំងមូលដែលអាចយកទៅប្រើប្រាស់ជា ចំណេះដឹងក្នុងការកែលម្អការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់ខ្លួនឱ្យបានកាន់តែល្អប្រសើរថែមទៀត។ ហើយនៅក្នុងរបៀបវារៈចុងក្រោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើការបូកសរុបនូវលទ្ធផលនៃអង្គសន្និបាតទាំងមូល រួមជាមួយនឹងការបង្ហាញពីយុទ្ធសាស្ត្រ និងវិធីសាស្ត្រវិទ្យាសាស្ត្រថ្មីៗមួយចំនួនក្នុងការពន្លឿនការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យមានប្រសិទ្ធភាពទ្វេដងឆ្ពោះទៅសម្រេចបាននូវគោលដៅបីសូន្យ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ ការពិភាក្សា និងការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងចំណោមសមាជិក សមាជិកានៃអង្គសន្និបាត ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅពេលនេះ និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ឱ្យមានសុខភាពល្អ កម្លាំងមាំមួនក្នុងការចូលរួមពិភាក្សាឱ្យបានផុសផុល ដើម្បីទទួលបាននូវលទ្ធផលទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**សន្និបាតបូកសរុបការងារឆ្នាំ២០១៨ និងលើកទិសដៅសកម្មភាពឆ្នាំ២០១៩របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ។**